**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងធម្មការនិងសាសនា

លេខៈ ៧៣/២៤ ក.ធ.ស.ប្រក

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត

**រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងធម្មការនិងសាសនា
- បានឃើញអនុក្រឹត្យលេខ ១៥៤ អនក្រ.បក ចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ២០១១ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងធម្មការនិងសាសនា
- បានឃើញប្រកាសលេខ ១៩/១២ ក.ធ.ស.ប្រក ចុះថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់សៀវភៅកម្មវិធីពុទ្ធិកមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ថ្នាក់ឆ្នាំទី១-២-៣
- យោងតាមចំណារឯកភាពចុះថ្ងៃទី៨ ខែឧសភា ឆ្នាំ២០២៤ របស់រដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា ក្នុងលិខិតលេខ ១៤៣/២៤ អ.ព.ស.ជ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២៤ ស្តីពីផែនការប្រឡងសម្រាប់ឆ្នាំសិក្សា ២០២៤-២០២៥ របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ
- យោងតាមការចាំបាច់របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ

**សម្រេច**

**ប្រការ១.-**

មណ្ឌលប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត ត្រូវកំណត់ដោយក្រសួងធម្មការនិងសាសនា រៀងរាល់ឆ្នាំសិក្សា។

**ប្រការ២.-**

ប្រធានមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត និងនាយកគ្រឹះស្ថានពុទ្ធិកមធ្យមសិក្សាមានភារកិច្ចរៀបចំមណ្ឌលប្រឡង សំណុំឯកសារដែលពាក់ព័ន្ធ និងសម្ភារចាំបាច់សម្រាប់ការប្រព្រឹត្តទៅនៃការប្រឡងឱ្យហើយស្រេច មុនពេលបើកសម័យប្រឡង។

**ប្រការ៣.-**

មណ្ឌលប្រឡង ត្រូវមានប្រធាន អនុប្រធាន និងសមាជិកគណៈមេប្រយោគតាមភាពជាក់ស្តែង។



អាសយដ្ឋាន៖ វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់
ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ៖ (៨៥៥-២៣) ៧២២ ១៥៩
អ៊ីម៉ែល៖ mocargovkh@gmail.com
គេហទំព័រ៖ www.mocar.gov.kh

Scanned with CamScanner

**ប្រការ៤..**

សមាសភាពនិងលិខិតឧទ្ទេសនាមគណៈមេប្រយោគ ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា តាមការស្នើសុំរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ប្រការ៥..**

បន្ទប់ប្រឡងនីមួយៗ ត្រូវកំណត់បេក្ខសមណសិស្ស សិស្ស ទៅតាមចំនួនសមាមាត្រមិនឱ្យលើស ពី ២៥ រូប និងស្របតាមនីតិវិធីនៃគណៈកម្មការជំនាញ។

**ប្រការ៦..**

ប្រធានមណ្ឌលប្រឡងនីមួយៗ ជាអ្នកទទួលខុសត្រូវរួមក្នុងការប្រព្រឹត្តទៅនៃដំណើរការវិញ្ញាសា ទាំងផ្នែករដ្ឋបាល ទាំងផ្នែកបច្ចេកទេស ចំពោះមុខក្រសួងធម្មការនិងសាសនា។

**ប្រការ៧..**

ប្រធានមណ្ឌលប្រឡងនីមួយៗ ត្រូវសហការជាមួយកងកម្លាំងអាជ្ញាធរមានសមត្ថកិច្ច ដើម្បីរក្សា សន្តិសុខនិងរបៀបរៀបរយក្នុងពេលប្រឡង។

**ប្រការ៨..**

ក្នុងករណីមណ្ឌលប្រឡងមានភាពមិនប្រក្រតី ប្រធាន ឬអនុប្រធានមណ្ឌល ត្រូវរាយការណ៍ជា បន្ទាន់មកប្រធានគណៈមេប្រយោគទូទាំងប្រទេស ដើម្បីដោះស្រាយ ឬសុំការសម្រេចពីក្រសួងធម្មការ និងសាសនា។

**ប្រការ៩..**

ប្រធានមណ្ឌលត្រូវបែងចែកភារកិច្ចដល់អនុប្រធាននិងសមាជិក ហើយត្រូវអនុវត្តតាមតួនាទីរៀងៗខ្លួន។

**ប្រការ១០..**

សេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការប្រឡង មានចែងអំពីតួនាទីនិងភារកិច្ចរបស់ គណៈមេប្រយោគនិងគណៈកម្មការគ្រប់ផ្នែក។

**ប្រការ១១..**

អនុញ្ញាតឱ្យចុះឈ្មោះប្រឡងបានតែសមណសិស្ស សិស្ស ថ្នាក់ឆ្នាំទី៣ ប៉ុណ្ណោះ សម្រាប់ពុទ្ធិកអនុវិទ្យាល័យ ត្រូវមានវិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា (បាលីរង) ឬវិញ្ញាបនបត្របណ្តោះអាសន្នពុទ្ធិកបឋមសិក្សា ព្រមទាំងមធ្យមភាគពិន្ទុប្រចាំឆ្នាំ។ ចំណែកឯពុទ្ធិកវិទ្យាល័យ ត្រូវមានសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ (ឪប្តូម) ឬវិញ្ញាបនបត្របណ្តោះអាសន្នពុទ្ធិកមធ្យមសិក្សាបឋមភូមិព្រមទាំងមធ្យមភាគពិន្ទុប្រចាំឆ្នាំ។ ពាក្យសុំចុះឈ្មោះត្រូវស្នើសុំទៅរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា។

**ប្រការ១២..**

បេក្ខសមណសិស្ស សិស្សសេរី អាចសុំចុះឈ្មោះប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទាំងពីរកម្រិត បាន លុះត្រាតែជាអតីតបេក្ខសមណសិស្ស សិស្សដែលប្រឡងធ្លាក់សញ្ញាបត្រឆ្នាំកន្លងមក។

**ប្រការ១៣..**

បេក្ខសមណសិស្ស សិស្សសេរី ត្រូវដាក់ពាក្យស្នើសុំប្រឡងនៅតាមមន្ទីរធម្មការនិងសាសនា

រាជធានី ខេត្ត ឬផ្នែកពុទ្ធិកមធ្យមសិក្សា ដែលសាមីខ្លួនធ្លាប់បានសុំប្រឡងពីមុនមក។ សម្រាប់ការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ត្រូវភ្ជាប់វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា (បាលីរង) ឬវិញ្ញាបនបត្របណ្តោះអាសន្នពុទ្ធិកបឋមសិក្សា ចំណែកឯការប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ត្រូវភ្ជាប់វិញ្ញាបនបត្របញ្ជាក់ការសិក្សាថ្នាក់ទី១២។

**ប្រការ១៤..**

ពាក្យសុំចុះឈ្មោះប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ នឹងត្រូវប្រមូលផ្តុំនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សាដែលខ្លួនសិក្សា។ នាយកគ្រឹះស្ថាននីមួយៗត្រូវប្រមូលសំណុំលិខិតរបស់បេក្ខសមណសិស្ស សិស្ស បញ្ជូនទៅមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត រួចបញ្ជូនបន្តមកមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ដែលទទួលបន្ទុករៀបចំមណ្ឌលប្រឡង ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខសមណសិស្ស សិស្ស តាមលំដាប់អក្ខរក្រមហើយបញ្ជូនមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។ ដោយឡែកមណ្ឌលរាជធានីភ្នំពេញ ស្ថិតនៅក្រោមការរៀបចំនិងទទួលខុសត្រូវផ្ទាល់របស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ប្រការ១៥..**

ពាក្យសុំចុះឈ្មោះប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ នឹងត្រូវប្រមូលផ្តុំនៅតាមគ្រឹះស្ថានពុទ្ធិកសិក្សាដែលខ្លួនសិក្សា។ នាយកគ្រឹះស្ថាននីមួយៗត្រូវប្រមូលសំណុំលិខិតរបស់បេក្ខសមណសិស្ស សិស្សបញ្ជូនទៅអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ តាមរយៈមន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ដើម្បីធ្វើការបែងចែកនាមត្រកូលបេក្ខសមណសិស្ស សិស្ស តាមលំដាប់អក្ខរក្រម។

**ប្រការ១៦..**

សំណុំលិខិតដែលបេក្ខសមណសិស្ស សិស្ស ត្រូវភ្ជាប់មកមាន៖

ក-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ

| | |
|---|---|
| - ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| - ជីវប្រវត្តិសង្ខេប | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់ការសិក្សា | ចំនួន ០១ ច្បាប់ |
| - សលាកបត្រឯកត្តជន មានបិទរូបថតទំហំ (៤x៦) | ចំនួន ០២ សន្លឹក |
| - រូបថតថ្មី Digital យក (Soft Copy)ផ្ទៃក្រោយពណ៌ខៀវ | ចំនួន ០១ ប៉ុស្តិ៍ |
| - រូបថតថ្មី(៤x៦)(ថតយ្លុំចីវរចំពីមុខ ពាក់អាវស មិនពាក់វ៉ែនតា និងមិនពាក់ក្រវ៉ាត់ក) | ចំនួន ០២សន្លឹក |
| - សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្តីចម្លងសំបុត្រកំណើត ឬសេចក្តីចម្លងសំបុត្របញ្ជាក់កំណើត (ច្បាប់ថតចម្លង) | ចំនួន ០១ ច្បាប់ |
| - វិញ្ញាបនបត្រពុទ្ធិកបឋមសិក្សា ឬវិញ្ញាបនបត្របណ្តោះអាសន្នពុទ្ធិកបឋមសិក្សា (ច្បាប់ថតចម្លង) | ចំនួន ០១ ច្បាប់ |

ខ-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

| | |
|---|---|
| - ពាក្យសុំចុះឈ្មោះប្រឡង | ចំនួន ០១ ច្បាប់ |
| - ជីវប្រវត្តិសង្ខេប | ចំនួន ០១ ច្បាប់ |
| - លិខិតបញ្ជាក់ការសិក្សា | ចំនួន ០១ ច្បាប់ |



CS Scanned with CamScanner

- សលាកបត្រឯកត្តជន មានបិទរូបថតទំហំ (៤x៦) ចំនួន ០២ សន្លឹក
- រូបថត Digital (ផ្ទៃខាងក្រោយពណ៌ខៀវ) ចំនួន ០១ ប៉ុស្តិ៍
- រូបថត(៤x៦)(ថតឃ្លុំចីវរចំពីមុខ ពាក់អាវស មិនពាក់វ៉ែនតា និងមិនពាក់ក្រវ៉ាត់ក) ចំនួន ០២ សន្លឹក
- សំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ឬសេចក្ដីចម្លងសំបុត្រកំណើត ឬសេចក្ដីចម្លងសំបុត្របញ្ជាក់កំណើត (ច្បាប់ថតចម្លង) ចំនួន ០១ ច្បាប់
- សញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ឬវិញ្ញាបនបត្របណ្ដោះអាសន្នពុទ្ធិកមធ្យមសិក្សាបឋមភូមិ (ច្បាប់ថតចម្លង) ចំនួន ០១ ច្បាប់

**ប្រការ១៧.-**

មន្ទីរធម្មការនិងសាសនារាជធានី ខេត្ត ត្រូវពិនិត្យនិងផ្ទៀងផ្ទាត់ឈ្មោះ គោត្ត ថ្ងៃខែឆ្នាំកំណើត ទីកន្លែងកំណើត ឈ្មោះឪពុក ម្ដាយ ឱ្យបានច្បាស់លាស់និងធ្វើបញ្ជីរាយនាមបេក្ខសមណសិស្ស សិស្ស ផ្ញើមកអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ដើម្បីពិនិត្យនិងសម្រេចលើបេក្ខភាពប្រឡង។

**ប្រការ១៨.-**

បេក្ខសមណសិស្ស សិស្ស ត្រូវអនុវត្តតាមបទប្បញ្ញត្តិទូទៅស្ដីពីការប្រឡង ដែលមានចែងក្នុងបទដ្ឋានមួយដោយឡែក។

**ប្រការ១៩.-**

វិញ្ញាសា ថិរវេលា និងរបបពិន្ទុ នៃការប្រឡង នឹងត្រូវបានកំណត់ដូចតទៅ ៖

ក-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ

| | | |
|---|---|---|
| ១-ភាសាបាលី | រយៈពេល ១២០ នាទី | ៦០ ពិន្ទុ |
| ២-ភាសាខ្មែរ | រយៈពេល ១២០ នាទី | ៦០ ពិន្ទុ |
| ៣-គណិតវិទ្យា | រយៈពេល ១២០ នាទី | ៤០ ពិន្ទុ |
| ៤-ព្រះវិន័យនិងអភិធម្ម | រយៈពេល ៩០ នាទី | ៥០ ពិន្ទុ |
| ៥-ភាសាសំស្ក្រឹត | រយៈពេល ៦០ នាទី | ៤០ ពិន្ទុ |
| ៦-ភាសាអង់គ្លេស | រយៈពេល ៦០ នាទី | ៣០ ពិន្ទុ |
| ៧-រូបវិទ្យា | រយៈពេល ៦០ នាទី | ៣០ ពិន្ទុ |
| ៨-គីមីវិទ្យា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| ៩-ជីវវិទ្យា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| ១០-ផែនដីវិទ្យា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| ១១-ភូមិវិទ្យា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| ១២-ប្រវត្តិវិទ្យា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| ១៣-សីលធម៌ ពលរដ្ឋវិជ្ជា | រយៈពេល ៤៥ នាទី | ១៥ ពិន្ទុ |
| | សរុប | ៤០០ ពិន្ទុ |

ខ-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

| | | |
|---|---|---|
| ១-ភាសាបាលី | រយៈពេល ១២០ នាទី | ៦០ ពិន្ទុ |



Scanned with CamScanner

| | | | |
|---|---|---|---|
| ២-អក្សរសាស្ត្រខ្មែរ | រយៈពេល | ១២០ នាទី | ៦០ ពិន្ទុ |
| ៣-គណិតវិទ្យា | រយៈពេល | ១២០ នាទី | ៦០ ពិន្ទុ |
| ៤-សាសនាប្រៀបធៀប | រយៈពេល | ៩០ នាទី | ៥០ ពិន្ទុ |
| ៥-ព្រះអភិធម្ម | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ៦-ភាសាសំស្ក្រឹត | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ៧-ភាសាអង់គ្លេស | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ៨-រូបវិទ្យា | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ៩-គីមីវិទ្យា | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ១០-ជីវវិទ្យា | រយៈពេល | ៦០ នាទី | ៤០ ពិន្ទុ |
| ១១-ផែនដីវិទ្យា | រយៈពេល | ៤៥ នាទី | ២០ ពិន្ទុ |
| ១២-ភូមិវិទ្យា | រយៈពេល | ៤៥ នាទី | ២០ ពិន្ទុ |
| ១៣-ប្រវត្តិវិទ្យា | រយៈពេល | ៤៥ នាទី | ២០ ពិន្ទុ |
| ១៤-សីលធម៌ ពលរដ្ឋវិជ្ជា | រយៈពេល | ៤៥ នាទី | ២០ ពិន្ទុ |
| | សរុប | | ៥៥០ ពិន្ទុ |

សម្គាល់៖ វិញ្ញាសានីមួយៗ នឹងត្រូវបានពិន្ទុសូន្យចំពោះបេក្ខសមណសិស្ស សិស្ស អវត្តមាន ឬមិនបានប្រគល់សន្លឹកកិច្ចការដល់គណៈកម្មការអនុរក្ស។

**ប្រការ២០..**

អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ ជាអ្នកជ្រើសរើសនិងតាក់តែងវិញ្ញាសាប្រឡង ស្របតាមកម្មវិធីសិក្សាថ្នាក់ឆ្នាំទី៣ ទាំងពីរកម្រិត ហើយត្រូវដាក់ក្នុងស្រោមសម្ងាត់បិទជិតនិងប្រថាប់ត្រាជាផ្លូវការ។

**ប្រការ២១..**

ការប្រគល់និងការទទួលយកប្រធានវិញ្ញាសាប្រឡង ត្រូវមានការទទួលខុសត្រូវទាំងសងខាងដោយមានការចុះហត្ថលេខានិងឈ្មោះរវាងអ្នកប្រគល់និងអ្នកទទួល។

**ប្រការ២២..**

ចំនួនសន្លឹកវិញ្ញាសានីមួយៗ ត្រូវស្មើនឹងចំនួនបេក្ខសមណសិស្ស សិស្ស បើខ្វះ ត្រូវថតចម្លងបន្ថែមបង្គ្រប់ចំនួន។

**ប្រការ២៣..**

បន្ទាប់ពីបញ្ចប់ដំណើរការវិញ្ញាសាសរសេរ៖

ក-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ប្រធានមណ្ឌលប្រឡងនីមួយៗត្រូវប្រមូលសន្លឹកកិច្ចការបេក្ខសមណសិស្ស សិស្ស និងធ្វើកំណត់ហេតុស្ដីពីដំណើរការវិញ្ញាសាសរសេរ មកប្រគល់ឱ្យប្រធានមណ្ឌលកំណែ តាមរយៈបេសិតជនដែលចុះទៅពិនិត្យនិងតាមដានដំណើរការប្រឡងតាមមណ្ឌលនីមួយៗ។

ខ-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ប្រធានមណ្ឌលប្រឡងត្រូវប្រមូលសន្លឹកកិច្ចការបេក្ខសមណសិស្ស សិស្ស និងធ្វើកំណត់ហេតុស្ដីពីដំណើរការវិញ្ញាសាសរសេរ មកប្រគល់ឱ្យប្រធានមណ្ឌលកំណែ។



CS Scanned with CamScanner

**ប្រការ២៤..**

រាល់ដំណើរការកែវិញ្ញាសា ត្រូវប្រព្រឹត្តទៅនៅមណ្ឌលកំណែនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ប្រការ២៥..**

គណៈមេប្រយោគកំណែ ត្រូវចាត់តាំងបេក្ខភាពមួយរូប ជាប្រធានមណ្ឌលកំណែដែលមានភារកិច្ចគ្រប់គ្រងទូទៅនៅក្នុងមណ្ឌលកំណែទាំងមូល។

**ប្រការ២៦..**

ប្រធាន អនុប្រធានមណ្ឌលសំណេរ ត្រូវបន្តការងារនៅមណ្ឌលកំណែនិងអនុវត្តភារកិច្ចតាមការចាត់តាំងរបស់គណៈមេប្រយោគទូទាំងប្រទេសសំណេរ។

**ប្រការ២៧..**

មណ្ឌលកំណែត្រូវបែងចែកជាក្រុមតាមមុខវិជ្ជានីមួយៗប្រកបដោយតម្លាភាព។

**ប្រការ២៨..**

គណៈមេប្រយោគកំណែ មានភារកិច្ចចុះលេខនិងអក្សរសម្ងាត់លើសន្លឹកកិច្ចការរបស់បេក្ខសមណសិស្ស សិស្ស។

**ប្រការ២៩..**

រាល់សន្លឹកកិច្ចការរបស់បេក្ខសមណសិស្ស សិស្ស ត្រូវកែដោយសមាជិកកំណែពីររូបតាមតារាងអត្រាកំណែដែលប្រធានក្រុមកំណែតាមមុខវិជ្ជានីមួយៗបានកំណត់។

**ប្រការ៣០..**

ការស្រង់ពិន្ទុដោយដៃ ការបញ្ចូលទិន្នន័យក្នុងកុំព្យូទ័រ និងការផ្ទៀងផ្ទាត់លទ្ធផលប្រព្រឹត្តទៅនៅមណ្ឌលកំណែនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។

**ប្រការ៣១..**

ពិន្ទុប្រចាំឆ្នាំ ស្មើនឹងមធ្យមភាគពិន្ទុប្រចាំឆមាសទី១ បូកនឹងមធ្យមភាគពិន្ទុប្រចាំឆមាសទី២ រួចចែកនឹង២។ ពិន្ទុប្រឡងថ្នាក់ជាតិកំណត់ដូចខាងក្រោម៖

ក-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ ពិន្ទុសរុប ៥០០។

ខ-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ ពិន្ទុសរុប ៥៥០។

**ប្រការ៣២..**

របបពិន្ទុដែលប្រឡងជាប់ ត្រូវបានកំណត់ដូចខាងក្រោម៖

ក-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ

បេក្ខសមណសិស្ស សិស្ស ដែលមានពិន្ទុប្រឡងចាប់ពី ២៥០ ពិន្ទុឡើងទៅ ដោយមិនមានពិន្ទុសូន្យ ចំពោះវិញ្ញាសាណាមួយ។ របបពិន្ទុអតិបរមា ៤០០ ពិន្ទុនិងរបបពិន្ទុប្រចាំឆ្នាំ ១០០ ពិន្ទុ។ ពិន្ទុសរុប ៤០០ + ១០០ = ៥០០ ពិន្ទុ ហើយពិន្ទុជាប់គឺ ៥០០ ចែកនឹង ២ ស្មើនឹង ២៥០ ពិន្ទុ។ ៨២៥០



CS Scanned with CamScanner

ខ-ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

បេក្ខសមណសិស្ស សិស្ស ដែលមានពិន្ទុប្រឡងចាប់ពី ២៧៥ ពិន្ទុឡើងទៅ ដោយមិនមានពិន្ទុសូន្យចំពោះវិញ្ញាសាណាមួយ។

*ក្នុងករណីចាំបាច់ គណៈមេប្រយោគកំណែ អាចទម្លាក់មធ្យមភាគទៅតាមនីតិវិធីជាក់ស្តែង ក្រោយពីមានការស្នើសុំនិងឯកភាពពីក្រសួងធម្មការនិងសាសនា។

**ប្រការ៣៣..**

និទ្ទេសត្រូវបានកំណត់តាមពិន្ទុប្រឡងដូចតទៅ៖

ក.ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាបឋមភូមិ

និទ្ទេសមាន ៦ កម្រិត គឺ និទ្ទេសនីមួយៗត្រូវបានកំណត់ដូចខាងក្រោម ៖

ល្អប្រសើរ = ពិន្ទុសរុប x 0.៩ ល្អណាស់ = ពិន្ទុសរុប x 0.៨ ល្អ = ពិន្ទុសរុប x 0.៧ ល្អបង្គួរ = ពិន្ទុសរុប x 0.៦ មធ្យម = ពិន្ទុសរុប x 0.៥ ខ្សោយ (ធ្លាក់)

| ពិន្ទុសរុប | មេគុណកំណត់និទ្ទេស | ពិន្ទុសរុប | ប្រភេទនិទ្ទេស |
|---|---|---|---|
| ៥០០ | 0.៩ | ៤៥០ | (៤៥០-៥០០) ល្អប្រសើរ |
| ៥០០ | 0.៨ | ៤០០ | (៤០០-៤៤៩) ល្អណាស់ |
| ៥០០ | 0.៧ | ៣៥០ | (៣៥០-៣៩៩) ល្អ |
| ៥០០ | 0.៦ | ៣០០ | (៣០០-៣៤៩) ល្អបង្គួរ |
| ៥០០ | 0.៥ | ២៥០ | (២៥០-២៩៩) មធ្យម |
| ៥០០ | | <២៥០ | (<២៥០) ធ្លាក់ |

ខ.ប្រឡងសញ្ញាបត្រពុទ្ធិកមធ្យមសិក្សាទុតិយភូមិ

និទ្ទេសមាន ៦ កម្រិត គឺនិទ្ទេស **A, B, C, D, E** និង**F**។ និទ្ទេសនីមួយៗត្រូវបានកំណត់ដូចខាងក្រោម ៖

**A**:ល្អប្រសើរ = ពិន្ទុសរុប x 0.៩ **B**:ល្អណាស់ = ពិន្ទុសរុប x 0.៨ **C**:ល្អ = ពិន្ទុសរុប x 0.៧

**D**:ល្អបង្គួរ = ពិន្ទុសរុប x 0.៦ **E**:មធ្យម = ពិន្ទុសរុប x 0.៥ **F**:ខ្សោយ (ធ្លាក់)

| ពិន្ទុសរុប | មេគុណកំណត់និទ្ទេស | ពិន្ទុសរុប | ប្រភេទនិទ្ទេស |
|---|---|---|---|
| ៥៥០ | 0.៩ | ៤៩៥ | **A** (៤៩៥-៥៥០) ល្អប្រសើរ |
| ៥៥០ | 0.៨ | ៤៤០ | **B** (៤៤០-៤៩៤) ល្អណាស់ |
| ៥៥០ | 0.៧ | ៣៨៥ | **C** (៣៨៥-៤៣៩) ល្អ |
| ៥៥០ | 0.៦ | ៣៣០ | **D** (៣៣០-៣៨៤) ល្អបង្គួរ |
| ៥៥០ | 0.៥ | ២៧៥ | **E** (២៧៥-៣២៩) មធ្យម |
| ៥៥០ | | <២៧៥ | **F** (<២៧៥) ធ្លាក់ |

**ប្រការ៣៤..**

លទ្ធផលប្រឡង នឹងត្រូវបិទប្រកាសនៅតាមមណ្ឌលប្រឡង ឬផ្សព្វផ្សាយតាមរយៈផេកផ្លូវការរបស់អគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ។



CS Scanned with CamScanner

**ប្រការ៣៥..**

ព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ មានភារកិច្ចចុះហត្ថលេខាលើតារាងស្រង់ពិន្ទុ រីឯលទ្ធផលជាប់ធ្លាក់ជាស្ថាពរត្រូវចុះហត្ថលេខា ដោយព្រះអគ្គាធិការនិងរដ្ឋមន្ត្រីក្រសួងធម្មការនិងសាសនា។

**ប្រការ៣៦..**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៣៧..**

នាយកខុទ្ទកាល័យ ព្រះអគ្គាធិការនៃអគ្គាធិការដ្ឋានពុទ្ធិកសិក្សាជាតិ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការសាសនា អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ និងអង្គភាពពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តន៍ប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃចន្ទ ១២ កើត ខែអស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៤

រដ្ឋមន្ត្រី

ចាយ_បុរិន

**អន្លែងទទួល៖**

- -សម្តេចព្រះមហាសង្ឃរាជទាំងពីរគណៈ
- -គណៈសង្ឃនាយកទាំងពីរគណៈ
- -ទីស្តីការគណៈរដ្ឋមន្ត្រី
- -ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- -ក្រសួងមុខងារសាធារណៈ
- -ក្រសួងអប់រំ យុវជន និងកីឡា
- -ដូចប្រការ៣៧ ដើម្បីអនុវត្ត
- -ឯកសារ កាលប្បវត្តិ



CS Scanned with CamScanner